# ដំណាក់កាលត្រៀមៈ ការចាប់ផ្តើមចូលរៀនដោយមានទំនុកចិត្ត

## គោលការណ៍ណែនាំដើម្បីជួយដល់គ្រួសារក្នុងការបំពេញរបាយការណ៍ស្តីអំពីការសិក្សាត្រៀម និងការរីកចម្រើន *Transition Learning and Development Statement*

### ហេតុអ្វីបានជាការចាប់ផ្តើមចូលរៀនដោយមានទំនុកចិត្តមានសារៈសំខាន់?

ការចាប់ផ្តើមចូលរៀនដោយមានទំនុកចិត្ត នាំឱ្យមានលទ្ធផលរៀនសូត្រ និងសុខុមាលភាពល្អប្រសើរសម្រាប់កូនរបស់លោកអ្នក ទាំងអំឡុងពេលដំណាក់កាលត្រៀម និងបន្ទាប់ពីនេះ។ ការធានាពីដំណាក់កាលត្រៀមដ៏មានប្រសិទ្ធភាព ហើយមានទំនុកចិត្ត នឹងគាំទ្រផងដែរដល់និរន្តភាពនៃការរៀនសូត្រ និងការរីកចម្រើនរបស់កូនលោកអ្នកផងដែរ។ ការផ្តោតសារៈសំខាន់ទៅលើនិរន្តភាពនៃការរៀនសូត្រទទួលស្គាល់ថា ការបង្ខឹកហាត់ទំនុកបំរុងបន្ថែមទៅលើបទពិសោធន៍ពីមុន និងបច្ចុប្បន្នរបស់កូនលោកអ្នក នឹងជួយពួកគេឱ្យមានអារម្មណ៍សុវត្ថិភាព មានទំនុកចិត្ត និងមានទំនាក់ទំនងជាមួយមនុស្ស ទីកន្លែង ព្រឹត្តិការណ៍ ការបង្កើតទម្លាប់ និងការយល់ដឹងនានា។ ការចាប់ផ្តើមចូលរៀនដោយមានទំនុកចិត្ត មានទំនាក់ទំនងផ្ទាល់ជាមួយនឹងការលើកកម្ពស់ស្មារតីតស៊ូក្នុងចំណោមយុវជន។

### តើអ្វីទៅជារបាយការណ៍ស្តីអំពីការសិក្សាត្រៀម និងការរីកចម្រើន *TRANSITION LEARNING AND DEVELOPMENT STATEMENT?*

សេវាអប់រំកុមារវ័យតូច សាលា និងសេវាថែទាំក្រៅម៉ោងសាលា (OSHC) និងក្រុមគ្រួសារ គ្រប់គ្នាគឺជាដៃគូក្នុងការបណ្តុះស្មារតីរៀនសូត្រ និងសុខុមាលភាពរបស់កុមារ។ ដើម្បីបង្កលក្ខណៈកាន់តែងាយស្រួលក្នុងការចែករំលែកព័ត៌មានរវាងសេវាកម្ម សាលា និងក្រុមគ្រួសារនីមួយៗ Transition Learning and Development Statement (របាយការណ៍ស្តីអំពីការសិក្សាត្រៀម និងការរីកចម្រើន) នឹងត្រូវបានសរសេរដោយសេវាអប់រំកុមារវ័យតូចសម្រាប់កុមារទាំងអស់ ខណៈពេលពួកគេនឹងចូលសាលារៀន។

របាយការណ៍ស្តីអំពីការសិក្សាត្រៀម ចែករំលែកព័ត៌មានអំពីការរៀនសូត្រ ការរីកចម្រើន និងសុខុមាលភាពរបស់កូនលោកអ្នក ក្នុងចំណោមបណ្តាសេវាអប់រំកុមារវ័យតូច និងសាលា។ របាយការណ៍ស្តីអំពីការសិក្សាត្រៀមសង្ខេបពីចំណង់ចំណូលចិត្ត ជំនាញ និងសមត្ថភាពរបស់កូនលោកអ្នក ហើយកំណត់វិធីសាស្ត្រនីមួយៗ និងយុទ្ធសាស្ត្របង្រៀនដើម្បីគាំទ្រកូនរបស់លោកអ្នកក្នុងដំណើរការសិក្សារបស់ពួកគេ។

របាយការណ៍ស្តីអំពីការសិក្សាត្រៀម អាចជួយលោកអ្នកស្វែងយល់ គាំទ្រ ប្រាស្រ័យទាក់ទងអំពី និងគាំទ្រដល់ការរៀនសូត្ររបស់កូនលោកអ្នក ខណៈពេលដែលពួកគេឆ្លងកាត់ដំណាក់កាលត្រៀមចូលរៀន។ ព័ត៌មាននៅក្នុងរបាយការណ៍ស្តីអំពីការសិក្សាត្រៀម ជួយធ្វើឱ្យគ្រូថ្នាក់ត្រៀមយល់ស្គាល់ពីកូនរបស់លោកអ្នក និងរៀបចំគម្រោងកម្មវិធីសិក្សា និងបង្រៀនឱ្យសមស្រប។ ប្រសិនបើលោកអ្នកមានគម្រោងរៀបចំកូនរបស់លោកអ្នកឱ្យចូល OSHC របាយការណ៍ស្តីអំពីការសិក្សាត្រៀម ក៏អាចជួយអ្នកអប់រំ OSHC រៀបចំផែនការសម្រាប់ការចូលរួមរបស់កូនលោកអ្នកផងដែរនៅក្នុងសេវា OSHC និងគាំទ្រដល់និរន្តភាពរវាងបរិបទផ្សេងៗ។

របាយការណ៍ស្តីអំពីការសិក្សាត្រៀម មានផ្ទុកនូវព័ត៌មានផ្ទាល់ខ្លួនមួយចំនួន រួមមានឈ្មោះរបស់កូនលោកអ្នក ថ្ងៃខែឆ្នាំកំណើត និងរូបថត ព្រមទាំងឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់លោកអ្នក។ វាក៏អាចដាក់ឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់អ្នកជំនាញផ្នែកអប់រំកុមារវ័យក្មេងផ្សេងទៀតផងដែរ ដែលកំពុងជួយគាំទ្រកូនលោកអ្នក។

ការចូលរួមចំណែកក្នុងរបាយការណ៍ ស្តីអំពីការសិក្សាត្រៀមរបស់កូនលោកអ្នក គឺជាដំណាក់កាលមួយឈានទៅការធ្វើសកម្មភាពនានាតម្រូវដោយសាលា ដែលលោកអ្នក និងកូនរបស់លោកអ្នកអាចចូលរួមមុនពេលសាលាចាប់ផ្តើម និងក្នុងអំឡុងឆ្នាំសិក្សានេះ។

### តើខ្ញុំត្រូវបំពេញផ្នែកមួយណាក្នុងរបាយការណ៍ស្តីអំពីការសិក្សាត្រៀម?

*ផ្នែក 1* និង *1.1* ត្រូវបំពេញដោយអ្នកអប់រំកុមារវ័យក្មេងរបស់កូនលោកអ្នក។

*ផ្នែក 1.2* អាចបំពេញដោយអ្នកអប់រំកុមារវ័យក្មេងរបស់កូនលោកអ្នក ប្រសិនបើកូនរបស់លោកអ្នកមានភាពយឺតយ៉ាវនៃការរីកលូតលាស់ ឬពិការភាព។ អ្នកជំនាញផ្នែកអប់រំកុមារវ័យក្មេងផ្សេងទៀត ដែលជួយគាំទ្រដល់កូនរបស់លោកអ្នក ក៏អាចចូលរួមចំណែកក្នុងការបំពេញផ្នែកនេះផងដែរ។

*ផ្នែក 2: អំពីកូន* ត្រូវបំពេញដោយកូនរបស់លោកអ្នក ជាមួយមនុស្សពេញវ័យដែលគេស្គាល់ និងមានអារម្មណ៍ជិតដិត។ នេះអាចរាប់បញ្ចូលទាំងលោកអ្នក ឬអ្នកអប់រំកុមារវ័យក្មេងរបស់កូនលោកអ្នក។

*ផ្នែក 3: អំពីគ្រួសារ* គឺសម្រាប់លោកអ្នកបំពេញ។ វាមានសារសំខាន់ចំពោះលោកអ្នកដែលត្រូវចូលរួមចំណែកក្នុងការផ្តល់ទស្សនៈរបស់លោកអ្នក ទៅក្នុងរបាយការណ៍ស្តីអំពីការសិក្សាត្រៀមរបស់កូនលោកអ្នក។ ផ្នែកនេះមានសំណួរជាច្រើនសម្រាប់ជួយសួរនាំលោកអ្នក។ ការឆ្លើយសំណួរខ្លះ ឬទាំងអស់អាចជួយគ្រូរបស់កូនលោកអ្នក និងអ្នកអប់រំ OSHC (បើអនុវត្ត) ឆ្លើយតបដោយសមស្របទៅនឹងការរៀនសូត្រ និងការរីកចម្រើនរបស់កូនលោកអ្នក។

## តើមានអ្វីកើតឡើង បន្ទាប់ពីខ្ញុំបានបំពេញផ្នែករបស់ខ្ញុំក្នុងរបាយការណ៍ស្ដីអំពីការសិក្សាត្រៀម?

នៅពេលដែលលោកអ្នកបានបំពេញ*ផ្នែក 3: អំពីគ្រួសារ* សូមប្រគល់ផ្នែកនេះទៅឱ្យអ្នកអប់រំកុមារវ័យក្មេងរបស់កូនលោកអ្នក។ ប្រសិនបើលោកអ្នកបានជួយកូនរបស់លោកអ្នកបំពេញ*ផ្នែក 2: អំពីកូន* សូមប្រគល់ផ្នែកនេះជាមួយផ្នែក 3។

អ្នកអប់រំកុមារវ័យក្មេងរបស់កូនលោកអ្នក នឹងចងក្រងផ្នែកទាំងអស់នៃរបាយការណ៍ស្ដីអំពីការសិក្សាត្រៀម ហើយផ្ដល់ជូនលោកអ្នកនូវសេចក្ដីចម្លងដែលបានបំពេញរួចមួយច្បាប់។

អ្នកអប់រំកុមារវ័យក្មេងរបស់កូនលោកអ្នក ក៏នឹងចែករំលែកសេចក្ដីចម្លងនៃសេចក្ដីអធិប្បាយអំពីដំណាក់កាលឆ្លងកាត់ពេញលេញមួយច្បាប់ ជាមួយសាលា និងសេវា OSHC របស់កូនលោកអ្នក (បើអនុវត្ត)។

ប្រសិនបើលោកអ្នកមិនប្រាកដថា កូនរបស់លោកអ្នកនឹងចូលរៀនសាលាមួយណាទេ អ្នកអប់រំកុមារវ័យក្មេងរបស់កូនលោកអ្នកនឹងផ្ដល់ជូនលោកអ្នកនូវច្បាប់ចម្លងទីពីរនៃរបាយការណ៍ស្ដីអំពីការសិក្សាត្រៀមដើម្បីឱ្យលោកអ្នកអាចផ្ដល់ច្បាប់ចម្លងនោះទៅឱ្យសាលារបស់កូនលោកអ្នក នៅពេលលោកអ្នកចុះឈ្មោះកូនចូលរៀន។

ប្រសិនបើមិនបានប្រគល់ជូន *ផ្នែក 3: អំពីគ្រួសារ* ទៅអ្នកផ្ដល់សេវាកម្មទេ អ្នកអប់រំកុមារវ័យក្មេងរបស់កូនលោកអ្នក នឹងចែករំលែកផ្នែកដែលបានបំពេញរួចហើយជាមួយសាលារបស់កូនលោកអ្នក និងសេវា OSHC (បើអនុវត្ត) និងផ្ដល់ជូនលោកអ្នកនូវច្បាប់ចម្លងនៃព័ត៌មានដែលបានចែករំលែក សម្រាប់ឱ្យលោកអ្នករក្សាទុក។

ការស្រាវជ្រាវ និងមតិយោបល់ពីសាលារៀនបានបង្ហាញឱ្យដឹងថា ការចែករំលែកព័ត៌មាននេះ ជួយគាំទ្រដល់ដំណាក់កាលត្រៀមមុនចូលសាលារៀនដោយជោគជ័យ។ ទោះជាយ៉ាងណាក្ដី ប្រសិនបើលោកអ្នកមិនចង់ឱ្យព័ត៌មានពាក់ព័ន្ធណាមួយអំពីកូនរបស់លោកអ្នក ចែករំលែកជាមួយសាលារបស់កូនលោកអ្នកទេ សូមពិភាក្សាអំពីបញ្ហានេះ ជាមួយអ្នកអប់រំកុមារវ័យក្មេងរបស់កូនលោកអ្នក។

## សម្រាប់ព័ត៌មានបន្ថែម

សូមបើកចូលវិបសាយ
www.education.vic.gov.au/transitiontoschool

ឯកសារនេះត្រូវបានបកប្រែចេញជាភាសាសហគមន៍មួយចំនួន ដែលអាចទទួលយកបានពីវិបសាយ
www.education.vic.gov.au/transitiontoschool។